**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១២៧៤ .សសរ**

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់គម្រោងស្ថាបនាអាងពិព័រណ៍ត្រី និងមជ្ឈមណ្ឌលស្រាវជ្រាវមច្ឆាជាតិតំបន់ទន្លេមេគង្គ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់គម្រោងស្ថាបនាអាងពិព័រណ៍ត្រី និងមជ្ឈមណ្ឌលស្រាវជ្រាវមច្ឆាជាតិតំបន់ទន្លេមេគង្គ ដែលតទៅនេះហៅថា "គណៈកម្មការអន្តរក្រសួង" ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្ដម ជា សុផារ៉ា | ទេសរដ្ឋមន្ដ្រី រដ្ឋមន្ដ្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២. ឯកឧត្ដម វេង សាខុន | រដ្ឋមន្ដ្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣. ឯកឧត្ដម សុខ ចិន្ដាសោភា | រដ្ឋមន្ដ្រីប្រតិភូអមនាយករដ្ឋមន្ដ្រី អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធានប្រចាំការ |
| ៤. រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ដ្រី ១ រូប | | សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប | | សមាជិក |
| ៦. រដ្ឋលេខាធិការក្រសួងបរិស្ថាន ១ រូប | | សមាជិក |
| ៧. រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ១ រូប | | សមាជិក |
| ៨. តំណាងគណៈកម្មការទន្លេមេគង្គ ១ រូប | | សមាជិក |
| ៩. អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ | | សមាជិក |

គណៈកម្មការអន្ដរក្រសួង អាចមានសមាសភាពបន្ថែមមកពីក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់។

**ប្រការ២.-**

គណៈកម្មការអន្ដរក្រសួង មានភារកិច្ចដូចខាងក្រោម៖

- សហការ សម្របសម្រួល និងធ្វើការសិក្សាអំពីទីតាំង ផលប៉ះពាល់ និងកិច្ចការនានាពាក់ព័ន្ធចំពោះគម្រោងនេះ ជាមួយដៃគូជប៉ុន។
- ធ្វើរបាយការណ៍ពីលទ្ធផលការងារ និងលើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីសុំការណែនាំ។
- អនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣.-**

ប្រធានគណៈកម្មការអន្ដរក្រសួង ត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់។ ក្នុងករណីចាំបាច់ ប្រធានអាចកោះប្រជុំវិសាមញ្ញបាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធាន ឬអនុប្រធានប្រចាំការ ដែលបានទទួលសិទ្ធិពីប្រធាន ត្រូវដឹកនាំការប្រជុំរបស់គណៈកម្មការអន្ដរក្រសួងនេះ។

ប្រធានគណៈកម្មការអន្ដរក្រសួងនេះអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញ ចូលរួមពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការសិក្សាស្រាវជ្រាវ និងផ្ដល់យោបល់ តាមការចាំបាច់។

**ប្រការ៤.-**

គណៈកម្មការអន្ដរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារជាជំនួយការតាមការចាំបាច់។

**ប្រការ៥ .-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងកិច្ចដំណើរការការងាររបស់ខ្លួន ។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ៨ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ